# ព្រះរាជក្រឹត្យ

នស/រកត/១២១៧/១១៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់លទ្ធផល នៃការបោះឆ្នោតទុកចិត្តអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយអង្គសភា កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៧
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងជាប្រធាន អនុប្រធាន និងសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំង៖

១- ឯកឧត្តម **នុត សុខុម** ជាអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសឯកឧត្តម **គួយ ប៊ុនរឿន**

២- ឯកឧត្តម **ឌឹម សុវណ្ណារុំ** ជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសឯកឧត្តម រ៉ុង ឈុន

៣- ឯកឧត្តម **ហ៊ើល សារ៉ាត់** ជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសលោកជំទាវ **តែ ម៉ានីរ៉ុង**

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣** : សម្តេចអគ្គមហាសេនាបតីតេជោ... 

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឲ្យមានប្រសិទ្ធភាព។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

នស.រកត.១៧១២.១១៨៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៧*